


**Asian International Justice Initiative (AIJI), a project of East-West Center and the WSD Handa Center for Human Rights and International Justice at Stanford University (previously known as the UC Berkeley War Crimes Studies Center)**

# របាយការណ៍សង្ខេបប្រចាំសប្តាហ៍ លេខ ៣៣

នាសប្តាហ៍នេះ អង្គជំនុំជម្រះសាលាដំបូង បានស្តាប់សក្ខីកម្មរបស់សាក្សីឈ្មោះ **បាន សៀក** ក្នុងអំឡុងពេលពេញកម្មវិធីសវនាការចំនួនពីរថ្ងៃ។ ទោះបីជាគាត់បានបង្ហាញខ្លួនចំពេលពាក់កណ្តាលនៃផ្នែកជំនុំជម្រះក្តីលើការប្រព្រឹត្តចំពោះជនជាតិចាមក៏ដោយ ក៏សាក្សីរូបនេះត្រូវបានចោទសួរដេញដោលអំពីប្រធានបទផ្សេងៗទៀតផងដែរ រួមមាន៖ ការបោសសម្អាតកម្មាភិបាលភូមិភាគកណ្តាល (និង"ភូមិភាគឧត្តរចាស់") នៅឆ្នាំ១៩៧៧ និងកម្មាភិបាលភូមិភាគបូព៌ានៅឆ្នាំ១៩៧៨។ សាក្សីរូបនេះបានបដិសេធដែលថា ជនជាតិចាម ត្រូវបានកំណត់ជាក្រុមគោលដៅជាក់លាក់ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ដោយបានបញ្ជាក់ថា ប្រជាជនទាំងអស់ស្ថិតនៅលើ "ទូកតែមួយ"។ លោក **បាន សៀក** បានផ្តល់សក្ខីកម្មថា គាត់ត្រូវបានគេបញ្ជូនទៅភូមិភាគកណ្តាលនៃស្រុកចម្ការលើនៅក្នុងឆ្នាំ១៩៧៧ ដើម្បីកាន់តួនាទីជាអនុលេខាស្រុកនៅទីនោះ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់លេខាស្រុកឈ្មោះលោកស្រី **សូ សឿន** ដែលតួនាទីនេះ លោកស្រីបានបដិសេធក្នុងអំឡុងពេលផ្តល់សក្ខីកម្មដោយផ្ទាល់នៅចំពោះមុខអង្គជំនុំជម្រះនាពេលកន្លងមក។ ដូច្នេះហើយ ភាគច្រើននៃសក្ខីកម្មរបស់លោក **បាន សៀក** បានលើកឡើងទាក់ទងទៅនឹងសក្ខីកម្មរបស់លោកស្រី **សូ សឿន** ដែលជាសាច់ញាតិបង្កើតខាងប្រពន្ធរបស់គាត់ និងជាភរិយារបស់អតីតលេខាភូមិភាគកណ្តាលឈ្មោះ **កែ ពក**។ នៅថ្ងៃអង្គារពេលរសៀល អង្គជំនុំជម្រះ បានត្រៀមស្តាប់សក្ខីកម្មរបស់សាក្សីដែលជាជនជាតិចាមម្នាក់ទៀតគឺ លោក **សុះ រំលី** (មានអត្តលេខ 2-TCW-904) ក៏ប៉ុន្តែ ត្រូវបានក្រុមការពារក្តីលោក **នួន ជា** បដិសេធក្នុងការប្រើប្រាស់មេធាវីប្រឹក្សាដដែល គឺលោក **ឌុច ផារី** ដែលជាមេធាវីប្រឹក្សាឲ្យលោក **បាន សៀក** និងលោក **សុះ រំលី**។ ដោយសារតែមានការជូន

ដំណឹងខ្លីមួយថាមិនមានមេធាវីប្រឹក្សាណាម្នាក់នៅទំនេរ  អង្គជំនុំជម្រះសាលាដំបូង  បានសម្រេចផ្អាកសវនាការភ្លាមៗ និងបានប្រកាសនៅថ្ងៃពុធថា អង្គជំនុំជម្រះនឹងពន្យារពេលស្តាប់សក្ខីកម្មរបស់លោក **សុះ រំលី** ក៏ដូចជាសាក្សីបម្រុងម្នាក់ទៀតដែលមានអត្តលេខ 2-TCW-996 រហូតនៅក្រោយថ្ងៃសម្រាកបុណ្យភ្ជុំបិណ្ឌ។

---

* របាយការណ៍នេះ ត្រូវបានសរសេរដោយ អាឡិចសាន់ឌើ បេនហ្ស (Alexander Benz), ជា ប៉ូវ៉ាក់មុន្នី, ចូឌីស កាយសើ (Judith Kaiser), ដានៀល ម៉ាតថេស៍ (Daniel Mattes), ខេតលីន កាហ្វហ្វ្រៀ (Caitlin McCaffrie), នំ សុថារ័ត្ន, តាយលីណា, ភីនីឡូភី វ៉ាន់ ធូល (Penelope Van Tuyl) និង ថាលីសា ហ្ស៊ឺ ហូសេន (Talisa zur Hausen) ដែលជាផ្នែកមួយនៃកម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម និង ការផ្សព្វផ្សាយតាមសហគមន៍របស់អង្គការគម្រោង ផ្តួចផ្តើមយុត្តិធម៌អន្តរជាតិប្រចាំអាស៊ី (AIJI)។ AIJI គឺជាគម្រោងកិច្ចសហប្រតិបត្តិការរវាងមជ្ឈមណ្ឌលបស្ចិម-បូព៌ា (East-West Center) នៅអូណូឡូឡូ (Honolulu) និងមជ្ឈមណ្ឌល ដាប់ប៊ែលយូ.អេស.ឌី ហាន់ដា សម្រាប់សិទ្ធិមនុស្ស និង យុត្តិធម៌អន្តរជាតិ (WSD Handa Center) ដែលកាលពីមុន ត្រូវបានគេស្គាល់ថាជា មជ្ឈមណ្ឌលសិក្សាអំពីឧក្រិដ្ឋកម្មសង្គ្រាម ប៊ែកឃ្លី (Berkeley War Crime Study Center)។ ចាប់តាំងពីឆ្នាំ២០០៣មក មជ្ឈមណ្ឌលទាំងពីរនេះ បានកំពុងធ្វើកិច្ចសហប្រតិបត្តិការគ្នាលើគម្រោងជាច្រើនដែលពាក់ព័ន្ធនឹងការបង្កើតការផ្តួចផ្តើមយុត្តិធម៌  និងកម្មវិធីកសាងសមត្ថភាពនានាក្នុងវិស័យសិទ្ធិមនុស្សប្រចាំតំបន់អាស៊ីអាគ្នេយ៍នេះ។